May 17, 2019

# លោក ដាហ្គ អេរីចសិន គួរបញ្ឈប់កិច្ចសន្យាជាមួយរបបលោក ហ៊ុន សែន ឬចុះចេញពីតំណែង



សមាជិកព្រឹទ្ធសភាអាមេរិក ពីខាងគណបក្សសាធារណៈ នៅរដ្ឋវ៉ាស៊ីនតោន ស្តេត (Washington State) លោក ដាហ្គ អេរីចសិន (Doug Erickson) (ឆ្វេង) ជួបលោក ហ៊ុន សែន នាវិមានសន្តិភាព កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ រូបៈ ហ្វេសប៊ុកលោក ហ៊ុន សែន

**ដោយ មួង ណារ៉េត RFA 2019-05-16**

*ផ្នែកនិពន្ធនាយកនៃសារព័ត៌មាននៅរដ្ឋ* Washington State *ស្នើឲ្យលោកសមាជិកព្រឹទ្ធសភាថ្នាក់រដ្ឋលោក ដាហ្គ អេរិកសិន* (Doug Erickson) *បញ្ឈប់កិច្ចសន្យាជាមួយរបបលោក ហ៊ុន សែន ឬចុះចេញពីតំណែង ដោយសារការបំពានក្រមសីលធម៌របស់សមាជិកព្រឹទ្ធសភា និងគាំទ្ររបបមួយ ដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកមិនគាំទ្រ។*

*គណៈនិពន្ធនាយកនៃសារព័ត៌មាន ឌឹ ស៊ីអាធល ថៃមស៍* (the Seattle Times) *នៃរដ្ឋ* Washington State *ចុះផ្សាយកាលពីថ្ងៃទី១៤ ខែឧសភា ក្នុងនាមជាសមាជិកព្រឹទ្ធសភាថ្នាក់រដ្ឋមួយរូប ដែលពលរដ្ឋក្នុងស្រុករបស់គាត់បោះឆ្នោតឲ្យ គាត់ត្រូវតែបម្រើរាស្ត្រម្ចាស់ឆ្នោតក្នុងមណ្ឌលគាត់ មិនមែនបម្រើរដ្ឋាភិបាលបរទេសមួយ ដែលរងការរិះគន់ និងថ្កោលទោសជុំទិសថាជារបបដឹកនាំផ្តាច់ការ និង រំលោភសិទ្ធិមនុស្ស និងប្រជាធិបតេយ្យធ្ងន់ធ្ងរបែបនេះនោះទេ។*

*គណៈនិពន្ធនាយកដដែល បន្ថែមថា មេដឹកនាំសហគមន៍ខ្មែរនៅរដ្ឋ* Washington State *ខកចិត្តនឹងលោក ដាហ្គ អេរ៉ិចសិន យ៉ាងខ្លាំង ដែលបង្ហាញជំហរគាំទ្ររបបលោក ហ៊ុន សែន ដែលជារបបមិនស្របច្បាប់បែបនេះ។*

របបលោក ហ៊ុន សែន ជួលសមាជិកព្រឹទ្ធសភាថ្នាក់រដ្ឋរបស់អាមេរិក ពីខាងគណបក្សសាធារណៈ នៅរដ្ឋវ៉ាស៊ីនតោន លោក ដាហ្គ អេរិចសិន ដើម្បីពិគ្រោះយោបល់ និងជាភ្នាក់ងារបញ្ចុះបញ្ចូលមួយរូប ដើម្បីរបបក្រុងភ្នំពេញ។ លោក ដាហ្គ អេរិចសិន ស៊ីឈ្នួលឱ្យរបបលោក ហ៊ុន សែន នេះ ក្នុងនាមក្រុមហ៊ុនមួយរបស់លោកឈ្មោះ ផែករិម ប្រ៊ិចជឹះស៍ (PacRim Bridges) ដែលគិតថ្លៃ ៥០ម៉ឺន (៥០០.០០០) ដុល្លារក្នុងមួយឆ្នាំ ឬ ជាង ៤ម៉ឺនដុល្លារ (៤១.៦៦៦ ដុល្លារ) ក្នុងមួយខែ។

ពលរដ្ឋខ្មែរអាមេរិក និងជាអតិបាលរងក្រុងឡូវែល រដ្ឋម៉ាសាឈូសេត លោក នួន វាសនា ភ្ញាក់ផ្អើលដែលរបបលោក ហ៊ុន សែន ចំណាយលុយកន្លះលានដុល្លារមួយឆ្នាំ ដើម្បីជួលលោក ដាហ្គ អេរិចសិន ដែលជាការចាយវាយមិនចំណេញដល់ជាតិខ្មែរទេ តែចំណេញរបបនេះ ក្នុងការបំភ្លៃព័ត៌មាន អំពីទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក៕